ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ចាម
សំណុំរឿងព្រហ្មទណ្ឌលេខ: ៦៣
ចុះថ្ងៃទី២៦ ខែ មករា ឆ្នាំ២០១៩
សាលក្រមលេខ: **៦២៤** (ឆ)
ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៩

សាលក្រម
នាងនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងខេត្តកំពង់ចាម

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ ២០១៩ វេលាម៉ោងប្រាំបី និងសាមសិបប្រាំនាទី ដែលមានសមាសភាពដូចតទៅ ៖

ចៅក្រមជំនុំជម្រះ

-លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ចាម

តំណាងអយ្យការ

-លោក [redacted] តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ចាម

ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ចាម
-កញ្ញា [redacted] ជាមេធាវីការពារក្តីឲ្យជនជាប់ចោទឈ្មោះ [redacted] ណាំឈាវ
-លោកមេធាវី [redacted] គ្រូកម្មសិក្សាអមជាមួយផង

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ: ៦៣ អ.យ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] ណាំឈាវ ភេទប្រុស អាយុ២១ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកសិករ កើត និង រ [redacted] ខេត្តកំពង់ចាម ឪពុកឈ្មោះ [redacted] ឆេន (រ) ម្តាយឈ្មោះ [redacted] សៃ (រ) នៅលីវ ជានីតិជន ទោសពីមុនគ្មាន។

ជាប់ចោទពីបទ: **រក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិស្វាយ ឃុំស្វាយពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌ ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី ៤ នៃច្បាប់ស្តីពីការគ្រប់គ្រងគ្រឿងញៀន។

១.អង្គហេតុមានដូចតទៅ

កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង១៨ និង២០នាទី សមត្ថកិច្ចបានទទួលព័ត៌មានពីភ្នាក់ងារឈ្មោះ [redacted] ទី ភេទប្រុស អាយុ៣០ឆ្នាំ ថា: មានមុខសញ្ញាជួញដូរគ្រឿងញៀន នៅភូមិស្វាយ ឃុំស្វាយពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ក្រោយពីបានទទួលព័ត៌មានភ្លាម ដោយមានការអនុញ្ញាតពីលោក

ឧត្តមសេនីយ៍ស្នងការនគរបាលខេត្តកំពង់ចាម និងបានការឯកភាពយល់ព្រមពីលោក [redacted] ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តកំពង់ចាម សមត្ថកិច្ចបានរៀបចំកម្លាំងបើកកិច្ចប្រតិបត្តការ បង្ក្រាបបទល្មើសជាក់ស្តែង ករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដោយមានការឃ្លាំមើល និងញុះញង់អោយមានការលក់ទិញថ្នាំញៀនដោយខុសច្បាប់ដោយបានផ្តល់ប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ទៅកម្លាំងភ្នាក់ងារឈ្មោះ [redacted] ទី ដើម្បីទិញថ្នាំញៀនពីមុខសញ្ញាឈ្មោះ [redacted] ណាំឈាវ ភេទប្រុស អាយុ២១ឆ្នាំ និងបានណាត់ជួបទិញថ្នាំញៀននៅភូមិស្វាយ ឃុំស្វាយពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ រហូតដល់វេលាម៉ោង១៨ និង២០នាទី នាថ្ងៃខែឆ្នាំដដែល ពេលកម្លាំងភ្នាក់ងារទទួលថ្នាំញៀនពីឈ្មោះ [redacted] ណាំឈាវ នៅចំណុចណាត់ជួបខាងលើភ្លាមនោះសមត្ថកិច្ចដែលកំពុងឃ្លាំមើលបានចូលដេញចាប់ឈ្មោះ [redacted] ណាំឈាវ ដល់ចំណុចភូមិស្វាយ ឃុំស្វាយពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ក្នុងពេលឃាត់ខ្លួនបានជនសង្ស័យខាងលើ សមត្ថកិច្ចដកហូតបានវត្ថុតាងមាន៖ ប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ដោយបានការអនុញ្ញាតពីលោក [redacted] ព្រះរាជអាជ្ញារអមសាលាដំបូងខេត្តកំពង់ចាម សមត្ថកិច្ចបានបន្តធ្វើការឆែកឆេរផ្ទះជនសង្ស័យខាងលើ ដោយមានការចូលរួមពីមន្ត្រីមូលដ្ឋានក្នុងការឆែកឆេរ រកឃើញ៖ ម្សៅក្រាមពណ៌សសង្ស័យជាថ្នាំញៀនចំនួន៥កញ្ចប់ (ធំចំនួន៣កញ្ចប់ និងតូចចំនួន២កញ្ចប់) និងទូរស័ព្ទដៃម៉ាកណូគាអិនចុចពិលពណ៌ខៀវ១គ្រឿង។(ឯកសារលេខ:៤, ១៧)

-**បានឃើញ** ដីកាសន្និដ្ឋានស្តាពរលេខ:២១៤អ.យ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ចាម ។

-**បានឃើញ** ដីកាដំណោះស្រាយបញ្ជូនសំនុំរឿងទៅជំនុំជម្រះលេខ:៥៩៣ ព.ស ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ចាម ។

២.នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ណាំឈាវ បានឆ្លើយថា: ខ្ញុំបាទពុំបានលក់ថ្នាំញៀនទេ តែមានឈ្មោះយូ បានទូរស័ព្ទមកសុំចែកឲ្យបន្ទិចមក ពេលនោះខ្ញុំយកទៅឲ្យគាត់ ពេលត្រឡប់មកវិញបានចូលទិញទឹកក្រឡុកក៏ត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួន ហើយនាំទៅផ្ទះឆែកឆេរបានថ្នាំញៀនចំនួនប្រាំញាប់ ប្រាំមួយកញ្ចប់ទាំងមួយកញ្ចប់លក់ឲ្យគេ ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាន:

ក្រោយពីបានស្តាប់ការពិភាក្សាដេញដោលនាពេលសវនាការ និងចម្លើយជនជាប់ចោទនាគ្រប់តំណាក់កាល និងពិនិត្យភស្តុតាងផ្សេងៗក្នុងក្នុងសំណុំរឿង មានភាពស៊ីសង្វាក់ទៅនឹងរបាយការណ៍របស់សមត្ថកិច្ច ឃើញថា កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ នៅភូមិស្វាយ ឃុំស្វាយពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ពិតជាមានអង្គហេតុ រក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តដោយឈ្មោះ [redacted] ណាំឈាវ ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ សមត្ថកិច្ចធ្វើការឆែកឆេរ ឈ្មោះ [redacted] ណាំឈាវ ដកហូតបានថ្នាំញៀនចំនួន៦កញ្ចប់(ធំ ចំនួន៣កញ្ចប់ និង តូច ចំនួន៣កញ្ចប់) និងទូរស័ព្ទដៃម៉ាកណូគាអិនចុចពិល ពណ៌ខៀវ០១គ្រឿង ពិតប្រាកដមែន។

មានធាតុផ្សំ និងភស្តុតាងគ្រប់គ្រាន់ក្នុងការចោទប្រកាន់ទៅលើឈ្មោះ [redacted] **ណាំឈាវ** (មានសាវតារជាតិដូចខាងលើ)ពីបទ: **រក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិស្វាយ

ឃុំស្វាយពោធ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌ ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ដូច្នេះ តំណាងអយ្យការសូមតម្កល់បទចោទដូចមាននៅក្នុងដីកាសន្និដ្ឋានស្ថាពរលេខ:២១៤ព.ស ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ចាម ទុកជាបានការដដែល និងសូមតុលាការវិនិច្ឆ័យសេចក្តីទៅតាមច្បាប់ ។

<u>មេធាវីធ្វើសេចក្តីសន្និដ្ឋាន:</u>

ក្រោយពីបានស្តាប់ការពិភាក្សាដេញដោលនាពេលសវនាការ និងពិនិត្យភស្តុតាងដែលពាក់ព័ន្ធក្នុងសំណុំរឿង ឃើញថា កូនក្តីរបស់ខ្លួនបានឆ្លើយសារភាពពីកំហុសរបស់ខ្លួនហើយ ការដែលកូនក្តីរបស់ខ្លួនបានប្រព្រឹត្ត គឺដោយសារតែកូនក្តីរបស់ខ្លួនមានភាពឆោតល្ងង់ ពោលគឺការយល់ដឹងរបស់កូនក្តីខ្លួនមានកម្រិត ពុំអាចយល់ដឹងនូវអំពីដែលខ្លួនបានប្រព្រឹត្តថាជាបទល្មើដែលសង្គមស្អប់ខ្ពើម និងដែលច្បាប់បញ្ញាត្តិថាជាបទល្មើសត្រូវផ្តន្ទាទោសនោះទេ ដោយគ្រាន់តែជឿតាមគេបោកប្រើថានឹងបានកម្រៃបន្តិចបន្តួចសម្រាប់ជីវភាព ផ្ទុយទៅវិញប្រសិនបើដឹងថាជាបទល្មើស កូនក្តីរបស់ខ្លួនក៏មិនប្រព្រឹត្តនូវទង្វើនោះដែរ។ ម្យ៉ាងទៀតនាពេល សវនាការកូនក្តីរបស់ខ្លួនបានទទួលដឹងកំហុស និងបានសន្យាចំពោះមុខច្បាប់ថានឹងមិនប្រព្រឹត្តនូវអំពើដែលសង្គមស្អប់ខ្ពើមនោះទៀតឡើយ សុំតុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួនដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ស្នើសុំតុលាការមេត្តាបន្ធូរបន្ថយទោសដល់កូនក្តីខ្លួន ដើម្បីឲ្យកូនក្តីរបស់ខ្លួនមានឱកាសបានកសាងខ្លួន។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

សាលាដំបូងខេត្តកំពង់ចាម

-**យល់ឃើញថា:** ជនជាប់ចោទឈ្មោះ [redacted] **ណាំឈាវ ភេទប្រុស អាយុ២១ឆ្នាំ** (មានសាវតារជាតិដូចខាងលើ) ត្រូវបានចៅក្រមស៊ើបសួរចោទប្រកាន់បញ្ជូនមកជំនុំជម្រះ ពីបទ: **រក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិស្វាយ ឃុំស្វាយពោធ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ:៥៩៣ ព.ស ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ ។

-**យល់ឃើញថា:** តាមរបាយការណ៍លេខ ០១១/១៩ រ.ប.ក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលស្រុកស្រីសន្ធរ បានបង្ហាញថាឈ្មោះ [redacted] ណាំឈាវ ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ ពិតជាធ្វើសកម្មភាព រក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀនពិតមែន។(ឯកសារលេខ ១៧/៣)

-**យល់ឃើញថា:**ជនជាប់ចោទឈ្មោះ [redacted] **ណាំឈាវ** បានឆ្លើយសារភាពគ្រប់ដំណាក់កាលថា:

ខ្លួនចាប់ផ្តើមលក់ថ្នាំញៀននៅចុងឆ្នាំ២០១៨ ទិញម្តងៗចំនួន ២០០.០០០រៀល (ម្ភៃម៉ឺន)រៀល រួចហើយយកមករំលែលលក់ខ្លះ និងប្រើប្រាស់ខ្លះ នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង៦ល្ងាច មានឈ្មោះ យូ បានទូរស័ព្ទមករកទិញថ្នាំញៀនចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ខ្លួនក៏បានណាត់ និងប្រគល់ថ្នាំញៀន ពេលត្រឡប់មកវិញក៏ត្រូវសមត្ថកិច្ចចាប់ឃាត់ខ្លួនដកហូតទូរស័ព្ទដៃម៉ាក់ណូគាចំនួន០១គ្រឿង និងលុយចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ដែលខ្លួនទើបតែបានមកពីការលក់ថ្នាំឲ្យឈ្មោះ យូ ព្រមទាំងបន្តឆែកឆេរនៅផ្ទះរបស់ខ្លួនរកឃើញថ្នាំញៀនចំនួន៥កញ្ចប់ (តូចចំនួន២កញ្ចាប់ និងធំចំនួន៣កញ្ចប់) រួមទាំងថ្នាំដែលខ្លួនលក់ឲ្យឈ្មោះ យូ មួយកញ្ចប់តូចទៀតគឺប្រាំមួយកញ្ចប់ ដែលថ្នាំញៀនទាំងនេះខ្លួនទិញមកពីឈ្មោះ ជ្រុយ ភេទប្រុស អាយុប្រហែល២១ឆ្នាំ តាមរយៈទូរស័ព្ទ រាល់ការលក់ថ្នាំញៀនឲ្យគេខ្លួនមិនបានប្រាក់អីទេ បានត្រឹមជក់តែប៉ុណ្ណោះ។ (ឯកសារលេខ ៦, ២៦, ២៩)

ដូច្នេះ យើញថា សកម្មភាព និង អំពើរបស់ឈ្មោះ [redacted] **ណាំឈាវ** ភេទប្រុស អាយុ២១ឆ្នាំ ត្រូវបានច្បាប់ចាត់ទុកថាជា **អំពើល្មើសក្នុងបទ រក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ដូចមានចែងតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-**យល់ឃើញថា**: តាមកំណត់ហេតុចាប់ឃាត់ខ្លួន កំណត់ហេតុឆែកឆេរ សៀវភៅរូបភាពវត្ថុតាង កំណត់ហេតុចាប់យកវត្ថុតាង កំណត់ហេតុទទួលស្គាល់សម្ភារៈវត្ថុតាង ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលស្រុកស្រីសន្ធរ និងកំណត់ហេតុទទួលវត្ថុតាងរបស់អយ្យការអមសាលាដំបូងខេត្តកំពង់ចាម វត្ថុតាងដកហូតបានមាន: ម្សៅក្រាមពណ៌ស សង្ស័យជាថ្នាំញៀនចំនួន៦កញ្ចប់ (ធំចំនួន៣កញ្ចប់ និងតូច ចំនួន៣កញ្ចប់) និងទូរស័ព្ទដៃម៉ាកណូគាអិនចុចពិលពណ៌ខៀវមួយគ្រឿង (ឯកសារលេខ: ២, ៣, ៤, ៥, ៧, ៨, ១១, ២៣)។

-**យល់ឃើញថា**: តាមចម្លើយសារភាពរបស់ជនជាប់ចោទ [redacted] **ណាំឈាវ** មានភាពស៊ីសង្វាក់គ្នា និង កំណត់ហេតុឃាត់ខ្លួនជាក់ស្តែង របាយការណ៍របស់សមត្ថកិច្ច ព្រមទាំងភស្តុងតាងផ្សេងៗក្នុងសំណុំរឿង គឺជាអង្គហេតុ និង ភស្តុតាងបង្ហាញឲ្យតុលាការឃើញថា កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ សមត្ថកិច្ចបានចូលទៅធ្វើការឃាត់ខ្លួនឈ្មោះ [redacted] **ណាំឈាវ** ព្រមទាំងធ្វើការឆែកឆេរលើខ្លួនប្រាណ និងនៅផ្ទះរកឃើញម្សៅក្រាមពណ៌សសង្ស័យជាថ្នាំញៀនចំនួន៦កញ្ចប់ (ធំចំនួន៣កញ្ចប់ និងតូច ចំនួន៣កញ្ចប់) និងទូរស័ព្ទដៃម៉ាកណូគាអិនចុចពិល ពណ៌ខៀវ១គ្រឿង ប្រាកដមែន មានធាតុផ្សំជាបទ **រក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-**យល់ឃើញថា**: អំពើដែលជនជាប់ចោទឈ្មោះ [redacted] **ណាំឈាវ** ភេទប្រុស អាយុ២១ឆ្នាំ បានប្រព្រឹត្តកំណត់បានជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-**យល់ឃើញថា**: ជនជាប់ចោទឈ្មោះ [redacted] **ណាំឈាវ** ភេទប្រុស អាយុ២១ឆ្នាំ គឺជានីតិជន និងជាជនមានសមត្ថភាពក្នុងការយល់ដឹងគ្រប់គ្រាន់ដែលអាចទទួលខុសត្រូវចំពោះអំពើប្រព្រឹត្តរបស់ខ្លួនបាន។

-**យល់ឃើញថា**: មានធាតុផ្សំបទល្មើស និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **ណាំឈាវ** ភេទប្រុស អាយុ២១ឆ្នាំ (មានសាវតារជាតិដូចខាងលើ) ពីបទ: **រក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិស្វាយ ឃុំស្វាយពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម កាលពី

ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-**យល់ឃើញថា:** អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **ណាំឈាវ** បានប្រព្រឹត្តធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម ជាពិសេសជាគំរូអាក្រក់ដល់ក្មេងជំនាន់ក្រោយ ។

-**យល់ឃើញថា:** តំណាងអយ្យការសុំតម្កល់បទចោទតាមដីកាសន្និដ្ឋានស្តាពរលេខ:២១៤ព.ស ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ចាម ទុកជាបានការដដែល និងសូមតុលាការវិនិច្ឆ័យសេចក្តីទៅតាមច្បាប់ ។ គប្បីតុលាការលើកយកមកពិចារណា ។

-**យល់ឃើញថា:** វត្ថុតាងដែលរឹបអូសបានរួមមាន ម្សៅក្រាមពណ៌ស សង្ស័យជាថ្នាំញៀនចំនួន៦កញ្ចប់ (ធំចំនួន៣កញ្ចប់ និងតូចចំនួន៣កញ្ចប់) និងទូរស័ព្ទដៃម៉ាកណូគាអិនចុចពិលពណ៌ខៀវ១គ្រឿង ជាកម្មវត្ថុ និងជាមធ្យោបាយប្រព្រឹត្តបទល្មើស។ ហេតុដូច្នេះ គប្បីតុលាការសម្រេចរឹបអូសបំផ្លាញចោល។

<u>ហេតុដូច្នេះសម្រេច</u>

I-ផ្តន្ទាទោសឈ្មោះ [redacted] **ណាំឈាវ** ភេទប្រុស **អាយុ២១ឆ្នាំ** (មានសាវតារជាតិដូចខាងលើ) ជាក់ពន្ធនាគារកំណត់រយៈពេល **២ (ពីរ) ឆ្នាំ** គិតពីថ្ងៃឃាត់ខ្លួន ពីបទ **រក្សាទុក និងជួញដូរ ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិស្វាយ ឃុំស្វាយពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៤០** កថាខណ្ឌទី **៤** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

II-វត្ថុតាងមាន: ម្សៅក្រាមពណ៌ស (ថ្នាំញៀន) ចំនួន៦កញ្ចប់ (ធំចំនួន៣កញ្ចប់ និងតូច ចំនួន៣កញ្ចប់) និងទូរស័ព្ទដៃម៉ាកណូគាអិនចុចពិលពណ៌ខៀវ១គ្រឿង **រឹបអូសបំផ្លាញចោល** ។

III-សាលក្រមនេះ ជំនុំជម្រះនៅថ្ងៃពុធ ៨រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ត្រូវនឹងថ្ងៃទី២៤ ខែកក្កដា គ.ស២០១៩ និង ប្រកាសជាសាធារណៈ នៅថ្ងៃព្រហស្បតិ៍ ១៤រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២៩ ខែសីហា គ.ស២០១៩ ចំពោះមុខជនជាប់ចោទ បើកសិទ្ធប្តឹងទាស់ ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ក្រឡាបញ្ជីសវនាការ	**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា [redacted]	**ហត្ថលេខា និងត្រា** [redacted]

បានប្រៀបធៀប

ចៅក្រមជំនុំជម្រះ

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

កំពង់ចាម, ថ្ងៃទី២៩ ខែសីហា គ.ស២០១៩

ក្រឡាបញ្ជី

[redacted]

Scanned with CamScanner